ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ ៥៨៥ ក្រ១១"ង"
ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩
-សំណុំរឿងព្រហ្មទណ្ឌលេខ ៥៩០
ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ ៣៣១
ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខ ១៧៥៣
ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង០០ នាទី រសៀល ដោយមានសមាសភាព ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ក្រមប្រឹក្សា
លោក [redacted] ក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥៩០ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] សុខលាង ភេទប្រុស អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត[redacted] រាជធានីភ្នំពេញ មានទីលំនៅមុនឃាត់ខ្លួននៅបន្ទប់ជួលលេខ៨ ផ្លូវបេតុង សង្កាត់ទួលសង្កែ ទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុខា (រ) ម្តាយឈ្មោះ [redacted] ណាត់ (រ) ប្រពន្ធឈ្មោះ [redacted]ស៊ីណាត មានកូន០១នាក់ ជានីតិជន ទោសពីមុនមានពីបទលួច ។

ឃាត់ខ្លួនថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៧៦៩ "អ" ដ.ឃ.ដ ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៩។

លោកមេធាវី[redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ៩០CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះឈ្មោះ [redacted] ឡេង ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ អាសយដ្ឋានបច្ចុប្បន្នផ្ទះ លេខ ៩០CE0 ផ្លូវលេខ២១៤ ភូមិ២ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង២០និង០០នាទី នៅចំណុចមុខផ្ទះលេខ៩០ CE0 ផ្លូវលេខ ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ[redacted] សុខលាង បាន បើកម៉ូតូ០១គ្រឿងតែម្នាក់ឯង ម៉ាកស៊ុយហ្សុយគីឡេត ពណ៌ខៀវ មិនចាំស្លាកលេខ បានធ្វើសកម្មភាពឆក់យក កាបូបស្ពាយរបស់ជនរងគ្រោះឈ្មោះ [redacted] ឡេង ដែលបានទុកកាបូបស្ពាយពណ៌ទឹកប៊ិចនៅលើគ្រែ ហើយរើរ

ចូលទៅក្នុងផ្ទះរហូតបានសម្រេច ។ នៅក្នុងកាបូបនោះមានប្រាក់ខ្មែរ និងប្រាក់ដុល្លារអាមេរិកសរុប៥.000 (ប្រាំពាន់) ដុល្លារអាមេរិក, ខ្សែកផ្កាកទីនទម្ងន់១ជី, បន្តោងគុជចំនួន០១,ទូរស័ព្ទដៃម៉ាកអូប៉ូអេស៥ ចំនួន០១គ្រឿង ។ រហូតមកដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] សុខលាង ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-បានឃើញ របាយការណ៍សំយោគលេខ ៣៥/២០១៩ រ.ក.ប ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល-ផែនការងារនគរបាលព្រហ្មទណ្ឌនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៣៥០ អ.យ.ឃ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ១៥៤១ អ.យ.ឃ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២២៣៩ "ផ" ដ.ដ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុខលាង បានឆ្លើយថា៖ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង១៩និង៤០នាទី ខ្លួនបានជិះម៉ូតូម៉ាកស៊ុយហ្សុយគីឡេត ពណ៌ខៀវ មិនស្គាកលេខម្នាក់ឯងចេញពីផ្ទះនៅម្តុំកាំកូស៊ីធី ក្នុងគោលបំណងដើរលេង ។ ពេលខ្លួនជិះមកដល់ចំណុចផ្ទះលេខ៩០CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ បានឃើញមនុស្សស្រីម្នាក់ដាក់កាបូបស្ពាយពណ៌ទឹកប៊ិច នៅលើគ្រែចោលខាងមុនផ្ទះ រួចដើរចូលទៅក្នុងផ្ទះបាត់។ ខ្លួនក៏បានបើកម៉ូតូចូលទៅយកកាបូបនោះបានសម្រេច រួចក៏បើកម៉ូតូត្រឡប់ទៅកាំកូស៊ីធីវិញ ។ ពេលទៅដល់កន្លែងព្រៃស្ងាត់ខ្លួនបានបើកកាបូបមើលឃើញមានប្រាក់ដុល្លារចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក និងប្រាក់រៀលចំនួន ៤.000.000 (បួនលាន) រៀល,ទូរស័ព្ទដៃម៉ាកអូប៉ូ ពណ៌ស ចំនួន០១គ្រឿង និងឯកសារមួយចំនួនទៀត ។ ខ្លួនបានបោះកាបូបនោះចោល ហើយក៏ទៅដេកនៅផ្ទះសំណាក់នៅម្តុំពេទ្យរុស្សី ។ លុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ ប្រហែលម៉ោង ១២និង៣០នាទី ខ្លួនបានឲ្យទូរស័ព្ទម៉ាកអូប៉ូ ពណ៌សដែលឆក់បានឲ្យទៅឈ្មោះ ថាវី អាទប្រុស អាយុ២៨ឆ្នាំ យកទៅលក់បានប្រាក់ចំនួន១៣០ (មួយរយសាមសិប) ដុល្លារអាមេរិក ដោយឲ្យប្រាក់ទៅឈ្មោះ ថាវី ចំនួន១០ (ដប់) ដុល្លារអាមេរិក។ លុះនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង១៧និង២៥នាទី ខ្លួនបានត្រូវសមត្ថកិច្ចឃាត់ខ្លួន នៅចំណុចផ្ទះលេខ៩០CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-ជនរងគ្រោះឈ្មោះ [redacted] ឡេង បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង២០និង២០នាទី ខ្លួនបានមកលេងឪពុកម្តាយនៅផ្ទះលេខ៩០CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។ ពេលខ្លួនដើរចេញពីផ្ទះក្នុងបំណងត្រឡប់មកវិញ ខ្លួនបានឈរចាំម៉ូតូកង់បីនៅមុខផ្ទះដោយបានទុកកាបូបស្ពាយពណ៌ទឹកប៊ិចនៅលើគ្រែ ហើយបានដើរចូលទៅក្នុងផ្ទះយកឥវ៉ាន់ និងហៅម៉ូតូកង់បីជិះ។ ស្រាប់តែដាកមកវិញឃើញជនសង្ស័យជិះម៉ូតូបញ្ឆោសទិសតាមបណ្តោយផ្លូវ២១៤ តែម្នាក់ឯងធ្វើសកម្មភាពចូលយកកាបូបរបស់ខ្លួនដាក់នៅលើគ្រែយកទៅបាត់ ។ សម្ភារៈដែលបាត់បង់មានកាបូបស្ពាយពណ៌ទឹកប៊ិចមួយក្នុងនោះមានប្រាក់ដុល្លារ និងប្រាក់ខ្មែរសរុបចំនួន ៥.000(ប្រាំពាន់) ដុល្លារអាមេរិក, ខ្សែកផ្កាកទីនទម្ងន់០១ជី មានបន្តោងគុជចំនួន០១គ្រាប់,ទូរស័ព្ទដៃម៉ាកអូប៉ូR៥ចំនួន០១គ្រឿងពណ៌ស និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ០១សន្លឹក, លិខិតឆ្លងដែនចំនួន០១ក្បាល,សៀវភៅធនាគារចំនួន០៣ក្បាល។

សេចក្តីសន្និដ្ឋានបឹងសុំរបស់តំណាងអយ្យការ

ឆ្លងតាមអង្គសវនាការនេះឃើញថា: ជនជាប់ចោទឈ្មោះ [redacted] សុខលាង ពិតជាបានប្រព្រឹត្តអំពើ លួចមានស្តានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ៩០CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ

កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ប្រាកដមែន ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខណង បានប្រព្រឹត្តមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ ហេតុនេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ១៥៤១ អ.ឃ.ឃ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល និងស្នើសុំឲ្យតុលាការពិចារណាពីការមិនរាលចាលរបស់ជនជាប់ចោទ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការឃើញថា: កូនក្តីខ្លួនបានសារភាពនូវកំហុសរបស់ខ្លួននៅគ្រប់ដំណាក់កាលនៃនីតិវិធីថាខ្លួនពុំបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់របស់តំណាងអយ្យការទេ គឺកូនក្តីខ្លួនបានប្រព្រឹត្តអំពើ លួចកាបូបរបស់ជនរងគ្រោះដែលបានទុកនៅលើត្រែ ដោយពុំបានប្រើអំពើហិង្សា ឬឆក់កាបូបនោះទេ ។ ដូច្នេះ ខ្លួនសំណូមពរសុំឲ្យតុលាការមេត្តាកែប្រែការចោទប្រកាន់មកលើកូនក្តីខ្លួនពីបទ លួចមានស្ថានទម្ងន់ទោស តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទ លួច តាមមាត្រា៣៥៦ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌវិញ និងសំណូមរពរសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] សុខណង បាននិយាយសម្តីចុងក្រោយថា: ខ្លួនសំណូមពរសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផងពីព្រោះខ្លួនបានដឹងកំហុសរបស់ខ្លួនហើយ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាលើសំណុំរឿងបានត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខណង មានភាពស៊ីសង្វាក់គ្នាទៅនឹងអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ឡេង ព្រមទាំងភស្តុតាងផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងបានបញ្ជាក់ថា: កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង២០និង០០នាទី នៅចំណុចមុខផ្ទះលេខ៩០ Œ0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹតខណ្ឌ៧មករា រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] សុខណង ពិតជាបានបើកម៉ូតូចំនួន០១គ្រឿង ម៉ាកស៊ុយហ្សុយគីឡេត ពណ៌ខៀវ មិនចាំស្លាកលេខ បានធ្វើសកម្មភាពលួចយកកាបូបស្ពាយរបស់ជនរងគ្រោះឈ្មោះ [redacted] ឡេង ដែលបានទុកកាបូបស្ពាយពណ៌ទឹកប៊ិចនៅលើត្រែប្រាកដមែន។

អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខណង បានប្រព្រឹត្តពុំមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌទេ ។ ហេតុនេះ គប្បីតុលាការធ្វើការកែប្រែការចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទ លួច តាមមាត្រា៣៥២ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ។

២-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខណង បានប្រព្រឹត្តពុំមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ឡើយ ។

៣-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខណង បានបង្ហាញឲ្យឃើញថា ជនជាប់ចោទមានចេតនាទុច្ចរិត បង្កឲ្យមានការខូចខាតដល់សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខលាង** ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តជននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវអំពើរបស់ខ្លួន ចំពោះមុខក្រមព្រហ្មទណ្ឌជាធរមាន។

៥-តំណាងអយ្យការប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះគប្បីតុលាការពិចារណា។

៦-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុខលាង** ភេទប្រុស អាយុ១៩ឆ្នាំ សញ្ជាតិខ្មែរ ពីបទ **លួច** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៩0CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ តាមបញ្ជត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

៧-វត្ថុចាប់យកមានម៉ូតូចំនួន០១គ្រឿងម៉ាក SUZUSUKI LETS ពណ៌ក្រហម-ស លេខម៉ាស៊ីន ៤២៤៨២៥ លេខតួ ៤២៤៧៤១ ពាក់ស្លាកលេខ ១H១៣៩៨ ដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] សុខលាង នោះ គប្បីតុលាការពិចារណា និងសម្រេចតាមមាត្រា**៦២** និងមាត្រា**៦៣** នៃក្រមព្រហ្មទណ្ឌ។

៨-ផ្អែកតាមមាត្រា**៩៧** នៃក្រមព្រហ្មទណ្ឌ បានចែងថា "នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ" ។

<u>**ហេតុដូច្នេះតិនិច្ឆ័យសេចក្តី**</u>

១-កែប្រែការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **សុខលាង** ភេទប្រុស **អាយុ១៩ឆ្នាំ** សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៩0CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ តាមបញ្ជត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ មកជាពីបទ **លួច** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៩0CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ តាមបញ្ជត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌវិញ ។

២-ផ្តន្ទាទោសលើជនជាប់ចោទមានឈ្មោះ [redacted] **សុខលាង** ភេទប្រុស **អាយុ១៩ឆ្នាំ** សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ និង០៦ខែ (មួយឆ្នាំនិងប្រាំមួយខែ)** ពីបទ **លួច** ប្រព្រឹត្តនៅចំណុចផ្ទះលេខ៩0 CE0 ផ្លូវលេខ២១៤ ភូមិ២ ក្រុម៩ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ តាមបញ្ជត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

៣-វត្ថុចាប់យកមានម៉ូតូចំនួន០១គ្រឿងម៉ាក SUZUSUKI LETS ពណ៌ក្រហម-ស លេខម៉ាស៊ីន ៤២៤៨២៥ លេខតួ ៤២៤៧៤១ ពាក់ស្លាកលេខ ១H១៣៩៨ **ត្រូវរឹបអូសចូលជាទ្រព្យសម្បត្តិរដ្ឋ**។

៤-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី**២៣** ខែកក្កដា ឆ្នាំ**២០១៩** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុខលាង** និងប្រកាសជាសាធារណៈ នៅថ្ងៃទី**៣១** ខែកក្កដា ឆ្នាំ**២០១៩**។ **ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់**។

ក្រឡាបញ្ជីសវនាការ	**ចៅក្រមប្រឹក្សា**	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និង ត្រា	ហត្ថលេខា និងត្រា

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១៥រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]